**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**
គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩
ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩)
លេខ ២៩៩/២២ គ.វ.ក-១៩

ថ្ងៃចន្ទ ៥រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២

# សេចក្តីជូនព័ត៌មាន
## ស្តីពី
## ការក្រើនរំលឹក នៃការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋាន ដូសទី៣ ឬដូសជំរុញ សម្រាប់គ្រប់ក្រុមអាយុចាប់ពី ៣ឆ្នាំ ឡើង

យោងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ ក្នុងពិធីសម្ពោធស្ពាន ៧កន្លែងក្នុងខេត្តក្រចេះ និងខេត្តព្រៃវែង និងសារាចរណែនាំលេខ០២ស.រ. ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការពង្រឹងការអនុវត្តវិធានការប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលក្នុងសហគមន៍នៃវីរុសកូវីដ-១៩ ជាពិសេសវីរុសបំប្លែងថ្មីប្រភេទអូមីក្រុង ដើម្បីចូលរួមទប់ស្កាត់ការឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩ គ.វ.ក-១៩ សូមធ្វើការក្រើនរំលឹក និងអំពាវនាវយ៉ាងទទូចសាជាថ្មីម្តងទៀត ដល់កុមារ យុវវ័យ និងប្រជាពលរដ្ឋទាំងអស់ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២ រួចរាល់ ឬបានចាក់វ៉ាក់សាំងចនសុន និងចនសុន មួយដូសរួច ហើយមានគម្លាតចាប់ពី៤ខែឡើង បន្ទាប់ពីការចាក់វ៉ាក់សាំងដូសទី២ ឬបន្ទាប់ពីការចាក់វ៉ាក់សាំងចនសុន និងចនសុន មួយដូសរួច សូមប្រញាប់អញ្ជើញទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ ឱ្យបានគ្រប់ៗគ្នា នៅតាមមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព ឬទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ដែលស្ថិតនៅជិតទីសំណាក់របស់បងប្អូន និងក្មួយៗ។ សូមអាណាព្យាបាល មាតាបិតា នាំកុមារអាយុ ចាប់ពី ៣ឆ្នាំ ទៅក្រោម ៥ឆ្នាំ ទៅទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋានឱ្យបានគ្រប់ៗគ្នាចាប់ពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ នេះតទៅ និងការចាក់ដូសទី៣ ឬដូសជំរុញដល់កុមារក្រុមអាយុ ៥ឆ្នាំ ដល់ក្រោម ១២ឆ្នាំឱ្យបានគ្រប់ៗគ្នា ផងដែរ ចាប់ពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ នៅតាមទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ដែល គ.វ.ក-១៩ បានចេញសេចក្តីជូនព័ត៌មានកាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ និងដែលមានការណែនាំដោយឡែកតាមខេត្តនីមួយៗ ពីអនុគណៈកម្មការចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌរាជធានី-ខេត្តទាំង២៥។

ដើម្បីជំរុញល្បឿននៃការចាក់វ៉ាក់សាំងកូវីដ-១៩ ឱ្យបានលឿនឆាប់បានដល់ទិសដៅនៃក្រុមអាយុនីមួយៗ គ.វ.ក-១៩ សូមស្នើដល់ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត និងជាប្រធានអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌរាជធានី-ខេត្ត ព្រមទាំងឯកឧត្តម លោកជំទាវ លោកប្រធានមន្ទីរសុខាភិបាលរាជធានី-ខេត្តទាំងអស់ រួមទាំងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ យកចិត្តទុកដាក់បន្ថែមទៀតលើការងារជំរុញការចាក់វ៉ាក់សាំងកូវីដ-១៩ នៅតាមដែនសមត្ថកិច្ចរៀងៗខ្លួន ព្រមទាំងអនុវត្តនូវចំណុចសំខាន់ៗដូចតទៅ៖

– បន្តជំរុញការចាក់វ៉ាក់សាំងកូវីដ-១៩ និងបន្ថែមពេលវេលានៃការចាក់វ៉ាក់សាំងកូវីដ-១៩ ទាំងថ្ងៃសៅរ៍ ថ្ងៃអាទិត្យ និងថ្ងៃឈប់សម្រាក ក៏ដូចជាបន្តអប់រំផ្សព្វផ្សាយ ចលនា កៀរគរ ឱ្យប្រជាពលរដ្ឋបានយល់ និងបន្តទទួលការចាក់វ៉ាក់សាំងដូសទី៣



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

ឬដូសជំរុញ ព្រមទាំងចាត់ចែងយកវ៉ាក់សាំងទៅចាក់ជូនដល់ទីតាំងប្រជាពលរដ្ឋតាមភូមិ-ឃុំ តែម្តងក្នុងករណីពួកគាត់មិនអាចមកទទួលយកសេវាចាក់វ៉ាក់សាំងកូវីដ-១៩ បាននៅតាមទីតាំងចាក់វ៉ាក់សាំង ដោយសារមូលហេតុផ្សេងៗសមស្រប។

- ធ្វើបច្ចុប្បន្នភាពអ្នកមិនទាន់បានចាក់វ៉ាក់សាំងនៅតាមភូមិ-ឃុំ ឱ្យបានលឿន និងរៀបចំក្រុមគ្រូពេទ្យចុះចាក់ដល់ទីតាំងណាមួយដែលបានកៀរគររួចនោះ ដោយសហការជាមួយក្រុមគ្រូពេទ្យក្នុងការកំណត់ថ្ងៃចុះចាក់ឱ្យច្បាស់លាស់ (ដូចជា សាលារៀន រោងចក្រ-សហគ្រាស កន្លែងបំពេញការងារប្រមូលផ្តុំផ្សេងៗ) ឬអាចទៅចាក់ដល់ផ្ទះប្រជាពលរដ្ឋសម្រាប់ជនចាស់ជរា និងជនពិការ ដែលមិនអាចមកកាន់មូលដ្ឋានសុខាភិបាល ឬទីតាំងចាក់បាន។
- ត្រូវធ្វើការតាមដានលទ្ធផលចាក់វ៉ាក់សាំងជាប្រចាំថ្ងៃនៅតាមខេត្តរបស់ខ្លួន ហើយត្រូវជួយដោះស្រាយឱ្យមានប្រសិទ្ធិភាពនូវរាល់បាតុភាពយឺតយ៉ាវនានា ដែលអាចកើតមានដាយជាហេតុ សំដៅបង្កើននូវចំនួនអ្នកចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងល្បឿនលឿន ដែលអាចធ្វើទៅបាន។

ជាថ្មីម្តងទៀត ***គ.វ.ក-១៩*** សូមស្នើឱ្យរដ្ឋបាលរាជធានី-ខេត្ត និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់នៅទូទាំងប្រទេស ចាត់ចែងកៀរគរ ប្រជាជនដែលដល់វេនចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ ហើយមិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ ក៏ដូចជាអ្នកដែលមិនទាន់បានចាក់ដូសមូលដ្ឋាន ឬមិនទាន់បានចាក់ដូសទី២ នៅតាមមូលដ្ឋានរបស់ខ្លួនឱ្យមកទទួលយកការចាក់វ៉ាក់សាំងកូវីដ-១៩ វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋាន ដូសទី៣ ឬដូសជំរុញ នេះឱ្យបានគ្រប់គ្នា និងឱ្យបានឆាប់រហ័សតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដើម្បីបង្កើនភាពស៊ាំសម្រាប់បុគ្គល និងសម្រាប់សហគមន៍ ក្នុងការការពារ និងកាត់បន្ថយភាពរើលុកធ្ងន់ធ្ងរនៃជំងឺកូវីដ-១៩ ជាពិសេសវីរុសបំប្លែងខ្លួនថ្មីប្រភេទអូមីក្រុង ដែលកំពុងចរាចរយ៉ាងសកម្មនៅអំឡុងពេលបច្ចុប្បន្ននេះ និងជួយសង្គ្រោះអាយុជីវិត (Vaccine Safe Life) បងប្អូនកូនចៅយើងផងដែរ។

ទន្ទឹមគ្នានេះដែរ ***គ.វ.ក-១៩*** សូមគោរពជម្រាបជូនផងដែរថា ទោះបីជាបុគ្គលម្នាក់ៗបានទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ រួចហើយក្តី ក៏ត្រូវបន្តអនុវត្តនូវវិធានការ **«៣ការពារ»** (ពាក់ម៉ាស់ លាងដៃញឹកញាប់ និងរក្សាគម្លាតសុវត្ថិភាពបុគ្គលពី មួយម៉ែត្រកន្លះឡើងទៅ) និង **«៣កុំ»** (កុំទៅកន្លែងដែលមានមនុស្សច្រើនកុះករ កុំទៅកន្លែងដែលបិទជិតគ្មានខ្យល់ចេញចូល កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា) និងបន្តរួមគ្នាអនុវត្តតាមយុទ្ធនាការជាតិអប់រំក្រោមប្រធានបទ ***«រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩»*** ក៏ដូចជាគោរពតាមសេចក្តីណែនាំក្រើនរំលឹកចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ របស់ក្រសួងសុខាភិបាល ស្តីពីការបន្តការការពារការចម្លងវីរុសកូវីដ-១៩ ជាពិសេស អូមីក្រុង ដើម្បីចូលរួមទប់ស្កាត់ការចម្លងវីរុស កូវីដ-១៩ នៅក្នុងសហគមន៍នៃប្រទេសកម្ពុជា និងរក្សានិរន្តរភាពនៃការរស់នៅធម្មតាតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃការប្រយុទ្ធនឹងជំងឺកូវីដ-១៩។

**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការចំពោះកិច្ច**
**ចាក់វ៉ាក់សាំងកូវីដ-១៩ ជូនប្រជាជនទូទាំងប្រទេស(គ.វ.ក-១៩)**

**វេជ្ជបណ្ឌិត ឱ វណ្ណឌីន**



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩